**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)
## ស្តីពី
## យុទ្ធនាការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ (Sinovac) ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) សូមគោរពជម្រាបជូនដំណឹងជូនដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា ដោយសារតែស្ថានភាពជាក់ស្តែងនៃការរីករាលដាលជំងឺកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្នុងស្ថានភាពមួយដែលមិនទាន់មានការថមថយ និងត្រូវមានការប្រុងប្រយ័ត្នខ្ពស់ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវវិធានការនានា ដើម្បីទប់ស្កាត់ការចម្លងបន្តទៀត ជាពិសេស ក្រោមការគិតគូរ និងយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុងការទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ បានសម្រេចឱ្យធ្វើការបញ្ជាទិញវ៉ាក់សាំងស៊ីណូវ៉ាក់ (SINOVAC) ជំហានដំបូងក្នុងចំនួន ១.៥០០.០០០ដូស ពីសាធារណរដ្ឋប្រជាមានិតចិន ដែលកម្ពុជាទើបទទួលបាននៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ បន្ទាប់ពីទទួលបានជំនួយមនុស្សធម៌ដ៏ថ្លៃថ្លាពីសាធារណរដ្ឋប្រជាមានិតចិននូវវ៉ាក់សាំងស៊ីណូហ្វាម (Sinopharm) ចំនួន ១.០០០.០០០ដូស ដែលកន្លងមកកម្ពុជាទទួលបានចំនួន ៦០០.០០០ដូសរួចហើយ (នៅសល់ចំនួន ៤០០.០០០ដូសទៀតដែលនឹងមកដល់ជាបន្តបន្ទាប់នាពេលខាងមុខនេះ) ព្រមទាំងបានធ្វើកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូអន្តរជាតិនានា ដែលជម្រុញឱ្យកម្ពុជា អាចឈានទៅទទួលបានជាដំបូងផងដែរ នូវវ៉ាក់សាំងកូវីសែល (COVISHIELD) ដែលជាវ៉ាក់សាំងទទួលបានអាជ្ញាបណ្ណផលិតនៅឥណ្ឌាដោយអាស្ត្រាហ្សេនីកា (AstraZeneca) ផ្តល់ជាជំនួយតាមរយៈយន្តការមជ្ឈមណ្ឌលកូវ៉ាក់ (COVAX Facility) ដោយមានការសម្របសម្រួលពីអង្គការសុខភាពពិភពលោក (WHO) និងអង្គការយូនីសេហ្វ (UNICEF) ដែលកំពុងតែដំណើរការចាក់ជូនក្រុមមនុស្សអាយុ ៦០ឆ្នាំឡើង ហើយនឹងមានវ៉ាក់សាំងមកដល់ប្រទេសកម្ពុជាជាបន្តបន្ទាប់នាពេលខាងមុខនេះ គ.វ.ក-១៩ បាន និងកំពុងតែចាត់ចែងរៀបចំការចាក់ជូនប្រជាជនតាមក្រុមគោលដៅអាទិភាពដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល។

វ៉ាក់សាំងកូវីដ-១៩ ជាឧបករណ៍ថ្មីមួយបន្ថែមលើវិធានការសុខាភិបាលដែលមានស្រាប់ សម្រាប់ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងសង្គ្រោះជីវិតមនុស្ស ដោយជួយបុគ្គលមិនឱ្យឈឺធ្ងន់ធ្ងរនៅពេលឆ្លងជំងឺកូវីដ-១៩ និងកាត់បន្ថយការព្យាបាលនៅមន្ទីរពេទ្យ។ វ៉ាក់សាំងកូវីដ-១៩ ដែលកំពុងប្រើប្រាស់នៅព្រះរាជាណាចក្រកម្ពុជា ជាវ៉ាក់សាំងដែលបានធ្វើតេស្តពីសុវត្ថិភាព និងប្រសិទ្ធភាពម៉ត់ចត់ និងកំពុងប្រើប្រាស់នៅតាមបណ្តាប្រទេសនានាក្នុងតំបន់ និងក្នុងពិភពលោក ដែលបណ្តាប្រទេសមួយចំនួន បាន និងកំពុងតែដំណើរការចាក់បានរាប់សិបលាននាក់រួចទៅហើយដែរ។

អាស្រ័យហេតុនេះ គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) នាងខ្ញុំសូមអំពាវនាវដល់លោកតា លោកយាយ ពូ មីង ពុក ម៉ែ បងប្អូន និងក្មួយៗទាំងអស់ដែលមានអាយុចាប់ពី ១៨ឆ្នាំ ទៅដល់ ៥៩ឆ្នាំ ដែលជាក្រុមដល់វេនទទួលវ៉ាក់សាំងដូចមានរាយបញ្ជីខាងក្រោមនេះ សូមទៅទទួលចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្ត ដើម្បីការពារ



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ [illegible]

ខ្លួនអ្នក ការពារក្រុមគ្រួសារអ្នក និងការពារសហគមន៍យើង ដើម្បីកុំឱ្យវីរុសកូវីដ-១៩ វាយលុកចូលទៅក្នុងខ្លួនយើង ចូលទៅក្នុងផ្ទះរបស់យើង និងចូលសហគមន៍របស់យើង ដែលធ្វើឱ្យមានមហន្តរាយសុខភាពសាធារណៈ ក៏ដូចជាមានការប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ចគ្រួសារ ក៏ដូចជាសេដ្ឋកិច្ចជាតិរបស់យើងផងដែរ។

អនុវត្តន៍តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** គ.វ.ក.-១៩ បានកំណត់ក្រុមគោលដៅដែលត្រូវចាក់វ៉ាក់សាំងសរុបចំនួន ៧៤៥,០០០នាក់ (សម្រាប់ចំនួនដូសទី១) សម្រាប់ចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ (SINOVAC) ដោយត្រូវអនុវត្តន៍ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ ជូនក្រុមមនុស្សដែលដល់វេនចាក់នាពេលនេះ មានដូចតទៅ៖

១. ក្រុមគ្រូពេទ្យ បុគ្គលិក និងមន្ត្រីសុខាភិបាលជួរមុខ (សេវារដ្ឋ និងសេវាសុខាភិបាលឯកជនស្របច្បាប់ និងដែលមានបញ្ជីឈ្មោះត្រឹមត្រូវ បានផ្ញើជូន គ.វ.ក-១៩ ឬទៅមន្ទីរសុខាភិបាលរាជធានី-ខេត្ត រួចហើយ) ទាំងថ្នាក់ជាតិ និងក្រោមជាតិ ដែលពុំទាន់បានចាក់ពីមុន

២. រដ្ឋសភា ព្រទ្ធសភា និងក្រុមគ្រួសារ ដែលមានបញ្ជីឈ្មោះផ្ញើជូន គ.វ.ក-១៩ រួចហើយ

៣. អ្នកសារព័ត៌មានដែលពុំទាន់បានចាក់ពីមុន (ដែលមានបញ្ជីឈ្មោះត្រឹមត្រូវបានផ្ញើជូន គ.វ.ក-១៩ តាមរយៈក្រសួងព័ត៌មាន ឬទៅមន្ទីរសុខាភិបាលរាជធានី-ខេត្ត រួចហើយ)

៤. កងកម្លាំង និងមន្ត្រីមូលដ្ឋានគ្រប់លំដាប់ថ្នាក់ដែលពុំទាន់បានចាក់ពីមុននៅតាមរាជធានី-ខេត្ត (ចាំបាច់ត្រូវមានបញ្ជីឈ្មោះរៀបចំដោយអាជ្ញាធររាជធានី-ខេត្តពាក់ព័ន្ធ)

៥. មន្ត្រីរាជការស៊ីវិល រួមទាំងបុគ្គលិកកិច្ចសន្យាទាំងអស់នៅគ្រប់ក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងសាស្ត្រាចារ្យ-គ្រូបង្រៀននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលនានាទូទាំងប្រទេស (ដែលបានធ្វើសម្រង់បញ្ជីឈ្មោះដោយក្រសួងអប់រំ យុវជន និងកីឡា ដោយបានផ្ញើជូន គ.វ.ក-១៩ រួចហើយ)

៦. មន្ត្រី-បុគ្គលិកបម្រើការនៃអគ្គិសនីកម្ពុជាទូទាំងប្រទេស នៃអាជ្ញាធរជាតិទាំងអស់ នៃគណៈមេធាវី នៃសាលាក្តីខ្មែរក្រហម នៃលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រុមហ៊ុនអាកាសចរនានា ដែលបានផ្ញើបញ្ជីឈ្មោះជូន គ.វ.ក-១៩ រួចហើយ

៧. ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប កាណាឌីយ៉ាគ្រុប ដែលបានផ្ញើបញ្ជីឈ្មោះជូន គ.វ.ក-១៩ រួចហើយ

៨. កម្មករ-កម្មការិនីនៅតាមរោងចក្រមួយចំនួន (ទៅតាមវេន) ដែលសម្របសម្រួលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានផ្ញើជូន គ.វ.ក-១៩។

**តារាងកម្មវិធីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅតាមបណ្តាក្រសួង និងស្ថាប័នថ្នាក់ជាតិ៖**

| ល.រ | ឈ្មោះក្រសួង និង ស្ថាប័ន | ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត | ថ្ងៃខែឆ្នាំ | ទីតាំងចាក់វ៉ាក់សាំង |
|---|---|---|---|---|
| ១ | ក្រសួងអប់រំ យុវជន និង កីឡា ជាអ្នកចាត់ចែងក្រុមគ្រូបង្រៀន ទៅចាក់នៅតាមទីតាំងដូចខាងក្រោម ឱ្យមានសណ្តាប់ធ្នាប់៖ | | | |
| | | ក្រុមទី ១៖ គ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ (ជីតា) | ០១-០៩/មេសា/២១ | សាលាបឋមសិក្សាបាក់ទូក |
| | | ក្រុមទី ២៖ គ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ (ជីតា) | ០១-០៨/មេសា/២១ | សាលាបឋមសិក្សាកូលាប១ |
| | | ក្រុមទី ៣៖ គ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ (ជីតា) | ០១-១០/មេសា/២១ | វិទ្យាល័យផ្សារដើមថ្កូវ |
| | | ក្រុមទី ៤៖ គ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ (ជីតា) | ០១-១១/មេសា/២១ | វិទ្យាល័យទួលស្វាយព្រៃ |
| | | ក្រុមទី៥ និង៦៖ គ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ (ជីតា) | ០១-០៨/មេសា/២១ | វិទ្យាល័យ ជា ស៊ីម សន្ធរម៉ុក |
| | | ក្រុមទី ៩៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-១០/មេសា/២១ | សាលាបឋមសិក្សាស្ទឹងមានជ័យ |

| | | | | |
|---|---|---|---|---|
| | | ក្រុមទី ១០ និង ១១៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០៦/មេសា/២១ | វិទ្យាល័យច្បារអំពៅ |
| | | ក្រុមទី ១២៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-១០/មេសា/២១ | វិទ្យាល័យជាស៊ីម ជ្រោយចង្វារ |
| | | ក្រុមទី ១៣៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០៩/មេសា/២១ | វិទ្យាល័យឫស្សីកែវ |
| | | ក្រុមទី ១៤, ១៥ និង ១៦៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០៧/មេសា/២១ | សាលាបឋមសិក្សាភ្នំពេញថ្មី |
| | | ក្រុមទី ១៧៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-១០/មេសា/២១ | វិទ្យាល័យជម្ពូវ័ន្ត |
| | | ក្រុមទី ១៨៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០៦/មេសា/២១ | វិទ្យាល័យ ជា ស៊ីម ឈូកវ៉ា |
| | | ក្រុមទី ១៩៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-១០/មេសា/២១ | វិទ្យាល័យទួលអំពិល |
| | | ក្រុមទី ២០៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-១០/មេសា/២១ | សាលាបឋមសិក្សាកំបូល |
| | | ក្រុមទី ៧៖ គ្រូពេទ្យស្ម័គ្រចិត្ត សម្ដេចតេជោ (ជីតា) | ០១-១០/មេសា/២១ | សាលាបឋមសិក្សាចតុមុខ |
| ២ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ពន្ធដារ និង គយរដ្ឋាករ) | ក្រុមទី ៨៖ គ្រូពេទ្យស្ម័គ្រចិត្ត សម្ដេចតេជោ (ជីតា) | ០១-១០/មេសា/២១ | ទីស្ដីការក្រសួង |
| ៣ | ព្រឹទ្ធសភា និងកងអង្គរក្សវិមាន៧មករា | ក្រុមទី ២១៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០២/មេសា/២១ | វិមានព្រឹទ្ធសភា |
| ៤ | ក្រុមប្រឹក្សាធម្មនុញ | ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១/មេសា/២១ | វិមានព្រឹទ្ធសភា |
| ៥ | រដ្ឋសភា | ក្រុមទី ២១៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០៣-០៩/មេសា/២១ | វិមានរដ្ឋសភា |
| | ក្រុមគ្រួសារថ្នាក់ដឹកនាំរដ្ឋសភា | | | |
| ៦ | អាជ្ញាធរវនកម្មជាតិ | ក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្ដេចពិជ័យសេនា | ០៩-១០/មេសា/២១ | សណ្ឋាគារកោះពេជ្រ ឃីណា |
| ៧ | គ.ជ.ប | | ០៩-១០/មេសា/២១ | សណ្ឋាគារកោះពេជ្រ ឃីណា |
| ៨ | ក្រសួងបរិស្ថាន | ក្រុមទី ២២៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១/០៣/មេសា/២១ | ទីស្ដីការក្រសួង |
| ៩ | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច | ក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្ដេចពិជ័យសេនា | ០៦/មេសា/២១ | សណ្ឋាគារកោះពេជ្រ ឃីណា |
| ១០ | អាកាសចរស៊ីវិល | | ០៦/មេសា/២១ | សណ្ឋាគារកោះពេជ្រ ឃីណា |
| ១១ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ក្រុមទី ២៤ និង ២៥៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០៩/មេសា/២១ | ទីស្ដីការក្រសួង |
| ១២ | ទីស្ដីការគណៈរដ្ឋមន្ត្រី | ក្រុមគ្រូពេទ្យមន្ទីរពេទ្យកាល់ម៉ែត | ០២-១៥/មេសា/២១ | មន្ទីរពេទ្យកាល់ម៉ែត |

| | | | | |
|---|---|---|---|---|
| ១៣ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ | ក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្តេចពិជ័យសេនា | ០៧-០៨/មេសា/២១ | សណ្ឋាគារកាំបូឌីយ៉ាណា |
| ១៤ | ក្រសួងមុខងារសាធារណៈ | ក្រុមទី ២៨ និង ២៩៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០២/មេសា/២១ | សាលាភូមិន្ទរដ្ឋបាល |
| ១៥ | ក្រសួងពាណិជ្ជកម្ម | | ០៣-០៦/មេសា/២១ | ទីស្តីការក្រសួង |
| ១៦ | ក្រសួងទេសចរណ៍ | | ០៧-០៨/មេសា/២១ | ទីស្តីការក្រសួង |
| ១៧ | ក្រសួងព័ត៌មាន (អ្នកព័ត៌មានជាតិ និង អន្តរជាតិ) | ក្រុមទី ៣០ និង ៣១៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០៧/មេសា/២១ | ទីស្តីការក្រសួង |
| ១៨ | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | ក្រុមគ្រូពេទ្យមន្ទីរពេទ្យព្រះអង្គឌួង | ០២ -០៥/មេសា/២១ | មន្ទីរពេទ្យអង្គឌួង |
| ១៩ | ក្រសួងធម្មការ និង សាសនា | ក្រុមទី ៣២ និង ៣៣៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០២/មេសា/២១ | ទីស្តីការក្រសួង |
| ២០ | ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | | ០៣-០៨/មេសា/២១ | ទីស្តីការក្រសួង |
| ២១ | ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | | ០៩- ១០/មេសា/២១ | ទីស្តីការក្រសួង |
| ២២ | ក្រសួងសាធារណការ និង ដឹកជញ្ជូន | ក្រុមទី ៣៤ និង ៣៥៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០៥/មេសា/២១ | ទីស្តីការក្រសួង |
| ២៣ | ក្រសួងផែនការ | ក្រុមទី ២៣៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០៦-០៨/មេសា/២១ | ទីស្តីការក្រសួង |
| ២៤ | ក្រសួងព្រះបរមរាជវាំង | ក្រុមគ្រូពេទ្យកាល់ម៉ែត | ព្រឹក ០១/មេសា/២១ | មន្ទីរពេទ្យកាល់ម៉ែត |
| ២៥ | ក្រសួងអភិវឌ្ឍន៍ជនបទ | ក្រុមគ្រូពេទ្យមន្ទីរពេទ្យកាល់ម៉ែត | ០៩/មេសា/២១ | មន្ទីរពេទ្យកាល់ម៉ែត |
| ២៦ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | ក្រុមទី ៣៦៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០២/មេសា/២១ | ទីស្តីការក្រសួង |
| ២៧ | ក្រសួងយុត្តិធម៌ គុណកាកំពូល និង សាលាឧទ្ធរណ៍ | ក្រុមទី ៣៨៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០៥/មេសា/២១ | ទីស្តីការក្រសួង |
| ២៨ | ក្រសួងធនធានទឹក និងឧតុនិយម | | ០៦-០៩/មេសា/២១ | ទីស្តីការក្រសួង |
| ២៩ | ក្រសួងកិច្ចការនារី | ក្រុមគ្រូពេទ្យមន្ទីរពេទ្យព្រះអង្គឌួង | ១០- ១១/មេសា/២១ | មន្ទីរពេទ្យអង្គឌួង |
| ៣០ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | ក្រុមទី ៣៧៖ គ្រូពេទ្យស្ម័គ្រចិត្ត ស.គ.ស.ស.យ.ក | ០១-០៦/មេសា/២១ | ទីស្តីការក្រសួង |
| ៣១ | ក្រសួងរ៉ែ និងថាមពល | | ០៧-១០/មេសា/២១ | ទីស្តីការក្រសួង |
| ៣២ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ក្រុមគ្រូពេទ្យមន្ទីរពេទ្យកាល់ម៉ែត | ព្រឹក ០១/មេសា/២១ | មន្ទីរពេទ្យកាល់ម៉ែត |
| ៣៤ | អង្គភាពប្រឆាំងអំពើពុករលួយ | | ល្ងាច ០១/មេសា/២១ | |
| ៣៥ | ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុមនិងសភាពាណិជ្ជកម្មកម្ពុជា | ក្រុមទី ៤០, ៤១, ៤២, ៤៣ និង ៤៤៖ គ្រូពេទ្យស្ម័គ្រចិត្តសម្តេចពិជ័យសេនា | ០១-០៥/មេសា/២១ | សណ្ឋាគារកាំបូឌីយ៉ាណា |
| ៣៦ | ក្រុមហ៊ុនអាកាសចរណ៍នានា | ក្រុមទី ៤៥៖ គ្រូពេទ្យស្ម័គ្រចិត្តសម្តេចពិជ័យសេនា | ០៩-១០/មេសា/២១ | សណ្ឋាគារកាំបូឌីយ៉ាណា |
| ៣៧ | សេវាសុខាភិបាលឯកជន នៅភ្នំពេញ | ក្រុមទី ៤៦៖ គ្រូពេទ្យស្ម័គ្រចិត្តសម្តេចពិជ័យសេនា | ១៣-១៤/មេសា/២១ | សណ្ឋាគារកាំបូឌីយ៉ាណា |

| | | | | |
|---|---|---|---|---|
| ៣៨ | ក្រសួងសុខាភិបាល | | ០១-០៨/មេសា/២១ | មន្ទីរពេទ្យកុមារជាតិ |
| ៣៩ | ក្រសួងមហាផ្ទៃ | ក្រុមទី ៤៨ និង ៤៩៖ គ្រូពេទ្យស្ម័គ្រចិត្តសម្តេចពិជ័យសេនា | ០១- ១០/មេសា/២១ | ទីស្តីការក្រសួង |
| ៤០ | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា | ក្រុមទី ៥០ និង ៥១៖ គ្រូពេទ្យស្ម័គ្រចិត្តសម្តេចពិជ័យសេនា | ០១-០៨/មេសា/២១ | ទីស្តីការក្រសួង |
| ៤១ | អគ្គិសនីកម្ពុជា ( កន្លែងចាក់ អគ្គិសនីកម្ពុជា ) | ក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ ( ធីតា ) | ០១-០៩/មេសា/២១ | អគ្គិសនីកម្ពុជា |
| ៤២ | កាណាឌីយ៉ា គ្រុប និង OCIC Group | ក្រុមគ្រូពេទ្យស្ម័គ្រ ស.គ.ស.យ.ក | ០៥- ១៥/មេសា/២១ | ទីតាំងកោះពេជ្រ |
| ៤២ | ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | ក្រុមពេទ្យការងារ | | ទីស្តីការក្រសួង |
| ៤៣ | - អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអ្នកច្បាប់<br>-អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌<br>-អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ<br>-អគ្គលេខាធិការដ្ឋាននៃគណៈកម្មការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ។<br>-អគ្គលេខាធិការនៃអាជ្ញាធរ កម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន<br>-អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការ ជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។<br>-អគ្គលេខាធិការដ្ឋាននៃគណៈកម្មការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ។<br>-អគ្គលេខាធិការដ្ឋាន អចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការព្រំដែន<br>- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការជាតិប្រឆាំងភេរវកម្ម<br>- គណៈកម្មការសិទ្ធមនុស្សកម្ពុជា<br>-អង្គភាពព័ត៌មាននិងប្រតិកម្មរហ័ស<br>- អគ្គលេខាធិការដ្ឋាន នៃវេទិការសម្ព័ន្ធសង្គមស៊ីវិល។<br>-ក្រុមប្រឹក្សាវិសោធកម្មកងកំលាំងប្រដាប់អាវុធ។<br>-លេខាធិការដ្ឋាន នៃអង្គភាព អ្នកនាំពាក្យរដ្ឋាភិបាល។ | ក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្តេចពិជ័យសេនា | ១១-១២/មេសា/២១ | សណ្ឋាគារកាំបូឌីយ៉ាណា |

ក្រៅពីក្រុមខាងលើដែលមានការសម្របសម្រួលត្រឹមត្រូវពីក្រសួង-ស្ថាប័នសាមី ពីអង្គភាពរបស់ខ្លួន និងពីសាមីអាជ្ញាធរមូលដ្ឋានដើម្បីទៅចាក់វ៉ាក់សាំង នៅតាមទីតាំង និងតាមវេនកំណត់រៀងៗខ្លួននោះ សូមបងប្អូនដែលមិនស្ថិតនៅក្នុងក្រុមខាងលើនេះ សូមមេត្តាអធ្យាស្រ័យ ដោយសូមរង់ចាំដល់វេនរបស់ខ្លួន សឹមទៅចាក់ នៅពេលវ៉ាក់សាំងមកដល់លើកក្រោយៗទៀត ដើម្បីកុំឱ្យមានការកកស្ទះ កុះករពេក បង្កជាហានិភ័យនៃការចម្លងវីរុសកូវីដ-១៩។

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមគ្នាជាមួយក្រសួងសុខាភិបាល និងក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ កំពុងខិតខំស្វះស្វែងរកការទិញវ៉ាក់សាំងបន្ថែមទៀត ដើម្បីចាក់ជូនបងប្អូនប្រជាពលរដ្ឋទៅតាមផែនការ ១០លាននាក់។

ជាមួយគ្នានេះដែរ ទោះបីជាបុគ្គលម្នាក់ៗបានទទួលវ៉ាក់សាំងរួចហើយក្តី ក៏ត្រូវចងចាំថា ត្រូវតែបន្តចូលរួមត្រួតពិនិត្យ និងការពារហានិភ័យនៃការចម្លងជំងឺកូវីដ-១៩ កាត់បន្ថយផលប៉ះពាល់លើសេដ្ឋកិច្ច និងសង្គម ដោយបន្តអនុវត្តនូវការអនុវត្តវិធានការ **៣ការពារ** (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើង) និង **៣កុំ** (កុំទៅកន្លែងមានមនុស្សកុះករច្រើន កុំទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា) ដើម្បីចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងសហគមន៍ នៅក្នុងប្រទេសកម្ពុជា ដែលជាការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានបញ្ហាសុខភាព ឬមានជំងឺ ឬសង្ស័យថាមាការឆ្លងជំងឺ សូមប្រញាប់ទៅស្វែងរកការពិនិត្យពិគ្រោះនៅមន្ទីរពេទ្យរដ្ឋ ឬទំនាក់ទំនងតាមលេខផ្តល់ជូនខាងក្រោមនេះ។

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨។

ថ្ងៃពុធ ៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

**រដ្ឋលេខាធិការ និងជាប្រធាន គ.ម.ក-១៩**



ទីស្តីការក្រសួងសុខាភិបាល លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩